# Course: Applied Business Statistics

Week 3

Chapter 2. Probability (1)

Lecturer: Udam Prang, PhD, MEd

# មុខវិជ្ជា៖ ស្ថិតិធុរកិច្ចអនុវត្តន៍

## សប្តាហ៍ទី៣

## មេរៀនទី២. ប្រូបាប៊ីលីតេ (១)

គ្រូបង្រៀន៖ បណ្ឌិត ប្រាំង ឧត្តម

# មាតិកា

១. និយមន័យ (Definitions)

២. វិធីសាស្ត្រកំណត់តម្លៃប្រូបាប៊ីលីតេ (Approaches to Assign Probability to an Event)

© 2023 Udam Prang

# ១. និយមន័យ

ប្រូបាប៊ីលីតេ (Probability) | ព្រឹត្តិការណ៍ (Event)

# ប្រូបាប៊ីលីតេ

ប្រូបាប៊ីលីតេ (Probability) ជារង្វាស់មួយដែលប្រាប់ពីកម្រិតនៃលទ្ធភាព (Degree of Likelihood) ដែលព្រឹត្តិការណ៍ (Event) ណាមួយអាចនឹងកើតឡើង។

ប្រូបាប៊ីលីតេបង្ហាញពីកម្រិតនៃភាពជឿជាក់របស់យើង ពាក់ព័ន្ធនឹងការកើតឡើងរបស់ព្រឹត្តិការណ៍ណាមួយ។

# ប្រូបាប៊ីលីតេ

ប្រូបាប៊ីលីតេនៃព្រឹត្តិការណ៍ណាមួយត្រូវស្ថិតនៅចន្លោះលេខសូន្យ និង លេខមួយ។

ប្រសិនបើប្រូបាប៊ីលីតេនៃព្រឹត្តិការណ៍នោះខិតទៅរកសូន្យ, កម្រិតនៃភាពជឿជាក់របស់យើងទៅលើ "ការកើតឡើងនៃព្រឹត្តិការណ៍នោះ" កាន់តែធ្លាក់។

ប្រសិនបើប្រូបាប៊ីលីតេនៃព្រឹត្តិការណ៍នោះខិតទៅរកមួយ, កម្រិតនៃភាពជឿជាក់របស់យើងទៅលើ "ការកើតឡើងនៃព្រឹត្តិការណ៍នោះ" កាន់តែកើន។

# ប្រូបាប៊ីលីតេ

ប្រូបាប៊ីលីតេ តាងដោយអក្សរ P។

ប្រសិនបើព្រឹត្តិការណ៍ណាមួយតាងដោយអក្សរ A, ប្រូបាប៊ីលីតេនៃព្រឹត្តិការណ៍នោះ តាងដោយអក្សរ P(A)។

- ប្រសិនបើ P(A) = 0, យើងប្រាកដចិត្តថាព្រឹត្តិការណ៍នោះមិនកើតឡើងទេ។
- ប្រសិនបើ P(A) = ១, យើងប្រាកដចិត្តថាព្រឹត្តិការណ៍នោះនឹងកើតឡើង។

© 2023 Udam Prang

# ព្រឹត្តិការណ៍

តាមគោលគំនិតរបស់ប្រូបាប៊ីលីតេ, ព្រឹត្តិការណ៍ គឺជា ព្រឹត្តិការណ៍ដែលអាចនឹងកើតឡើង មិនមែនជាព្រឹត្តិការណ៍ដែលបានកើតឡើងរួចមកហើយនោះទេ។

ហេតុដែលនាំឱ្យមានព្រឹត្តិការណ៍ គឺ សកម្មភាព ហើយសកម្មភាពនេះ ត្រូវបានអ្នកស្ថិតិហៅថាជា ការពិសោធ (Experiment)។

ព្រឹត្តិការណ៍ឆ្លុះបញ្ចាំងឱ្យឃើញពី លទ្ធផលដែលអាចទៅរួចបន្ទាប់ពីការពិសោធ។

ចំនួនលទ្ធផលដែលអាចទៅរួចបន្ទាប់ពីការពិសោធមានកំណត់ច្បាស់លាស់ ប៉ុន្តែចំនួន ព្រឹត្តិការណ៍ដែលអាចកើតឡើង មានច្រើនរាប់មិនអស់។

© 2023 Udam Prang

# ព្រឹត្តិការណ៍

ឧទាហរណ៍ លទ្ធផលដែលអាចទៅរួច បន្ទាប់ពីការប្រឡងមុខវិជ្ជាស្ថិតិ មានពីរគឺ លទ្ធផលជាប់ និង លទ្ធផលធ្លាក់។ ប៉ុន្តែ តាមគោលគំនិតប្រូបាប៊ីលីតេ ព្រឹត្តិការណ៍ដែលអាចកើតឡើង មានច្រើនដូចជា៖

- ព្រឹត្តិការណ៍ដែលបេក្ខជនម្នាក់ទទួលបានលទ្ធផលជាប់
- ព្រឹត្តិការណ៍ដែលបេក្ខជនម្នាក់ទទួលបានលទ្ធផលធ្លាក់
- ព្រឹត្តិការណ៍ដែលបេក្ខជនម្នាក់ទទួលបានលទ្ធផលជាប់ ឬ ធ្លាក់
- ព្រឹត្តិការណ៍ដែលបេក្ខជនពីរនាក់ទទួលបានលទ្ធផលជាប់
- ព្រឹត្តិការណ៍ដែលបេក្ខជនពីរនាក់ទទួលបានលទ្ធផលធ្លាក់។ល។

© 2023 Udam Prang

# ព្រឹត្តិការណ៍

តាមគោលគំនិតប្រូបាប៊ីលីតេ, ព្រឹត្តិការណ៍ មាន ប្រាំពីរ ប្រភេទ៖

- ប្រភេទទី១៖ ព្រឹត្តិការណ៍ធម្មតា (Simple Event)
- ប្រភេទទី២៖ ព្រឹត្តិការណ៍ដែលបំពេញបន្ថែមឱ្យព្រឹត្តិការណ៍មួយផ្សេងទៀត (The Complementary Event)
- ប្រភេទទី៣៖ ព្រឹត្តិការណ៍ដែលមិនអាចកើតឡើងទន្ទឹមគ្នា (Mutually Exclusive Events)

© 2023 Udam Prang
Not For Citation | For Educational Purposes Only

# ព្រឹត្តិការណ៍

តាមគោលគំនិតប្រូបាប៊ីលីតេ, ព្រឹត្តិការណ៍ មាន ប្រាំពីរ ប្រភេទ៖

- ប្រភេទទី៤៖ ព្រឹត្តិការណ៍ដែលកើតឡើងពីការបញ្ចូលគ្នា រវាងព្រឹត្តិការណ៍ពីរ ឬ ច្រើន ហើយការបញ្ចូលគ្នានេះបង្ហាញលទ្ធផលដែលអាចទៅរួចចំនួនពីរ ឬ ច្រើន (United Events)
- ប្រភេទទី៥៖ ព្រឹត្តិការណ៍ដែលកើតឡើងពីការបញ្ចូលគ្នារវាងព្រឹត្តិការណ៍ពីរ ឬ ច្រើន ហើយការបញ្ចូលគ្នានេះបង្ហាញលទ្ធផលដែលអាចទៅរួចទាំងអស់ (Exhaustive Events)

# ព្រឹត្តិការណ៍

តាមគោលគំនិតប្រូបាប៊ីលីតេ, ព្រឹត្តិការណ៍ មាន ប្រាំពីរ ប្រភេទ៖

- ប្រភេទទី៦៖ ព្រឹត្តិការណ៍ដែលកើតឡើងពីការប្រសព្វគ្នារវាងព្រឹត្តិការណ៍ពីរ ឬ ច្រើន (Intersected Events)
- ប្រភេទទី៧៖ ព្រឹត្តិការណ៍ដែលកើតឡើងក្នុងករណីដែលព្រឹត្តិការណ៍មួយទៀតបានកើតឡើង (Conditioned Events)

© 2023 Udam Prang

# ព្រឹត្តិការណ៍ប្រភេទទី១

ព្រឹត្តិការណ៍ប្រភេទទីមួយ គឺ ព្រឹត្តិការណ៍ធម្មតា។ ព្រឹត្តិការណ៍នេះ ឆ្លុះបញ្ចាំងឱ្យឃើញលទ្ធផលដែលអាចទៅរួច (Probable Outcome) បន្ទាប់ពីការពិសោធ ចំនួនមួយតែប៉ុណ្ណោះ។

ឧទាហរណ៍ **ព្រឹត្តិការណ៍ដែលបេក្ខជន ក ទទួលបានលទ្ធផលជាប់** គឺជា ព្រឹត្តិការណ៍ធម្មតា ដោយសារព្រឹត្តិការណ៍នេះឆ្លុះបញ្ចាំងឱ្យឃើញលទ្ធផលដែលអាចទៅរួចបន្ទាប់ពីការពិសោធចំនួនមួយតែប៉ុណ្ណោះ។

# ព្រឹត្តិការណ៍ប្រភេទទី២

ព្រឹត្តិការណ៍ប្រភេទទីពីរ គឺជា ព្រឹត្តិការណ៍ដែលបំពេញបន្ថែមឱ្យព្រឹត្តិការណ៍មួយផ្សេងទៀត។

ឧទាហរណ៍ **ព្រឹត្តិការណ៍ដែលបេក្ខជន ក ទទួលបានលទ្ធផលធ្លាក់** គឺជា ព្រឹត្តិការណ៍ដែលបំពេញបន្ថែមឱ្យ **ព្រឹត្តិការណ៍ដែលបេក្ខជន ក ទទួលបានលទ្ធផលជាប់**។

មូលហេតុ គឺ ដោយសារការបញ្ចូលគ្នារវាងព្រឹត្តិការណ៍ទាំងពីរឆ្លុះបញ្ចាំងពីលទ្ធផលទាំងអស់ដែលអាចទៅរួចបន្ទាប់ពីការប្រឡង។

© 2023 Udam Prang

# ព្រឹត្តិការណ៍ប្រភេទទី២

ប្រសិនបើយើងតាង **ព្រឹត្តិការណ៍ដែលបេក្ខជន ក ទទួលបានលទ្ធផលជាប់** ដោយ A។

យើងបាន ព្រឹត្តិការណ៍ដែលបំពេញបន្ថែមឱ្យព្រឹត្តិការណ៍ A តាងដោយ $A^c$។

នោះគឺ **ព្រឹត្តិការណ៍ដែលបេក្ខជន ក ទទួលបានលទ្ធផលធ្លាក់**។

# ព្រឹត្តិការណ៍ប្រភេទទី៣

ព្រឹត្តិការណ៍ប្រភេទទីបី គឺ ព្រឹត្តិការណ៍ដែលមិនអាចកើតឡើងទន្ទឹមគ្នា។

ឧទាហរណ៍ **ព្រឹត្តិការណ៍ដែលបេក្ខជន ក ទទួលបានលទ្ធផលជាប់** មិនអាចកើតឡើងទន្ទឹមគ្នាជាមួយនឹង **ព្រឹត្តិការណ៍ដែលបេក្ខជន ក ទទួលបានលទ្ធផលធ្លាក់** នោះទេ។ បុគ្គល ក តែម្នាក់ មិនអាចទទួលបានលទ្ធផលជាប់ផង និងលទ្ធផលធ្លាក់ផង សម្រាប់មុខវិជ្ជាតែមួយនោះទេ។

# ព្រឹត្តិការណ៍ប្រភេទទី៤

ព្រឹត្តិការណ៍ប្រភេទទី៤ គឺជា ព្រឹត្តិការណ៍ដែលកើតឡើងពីការបញ្ចូលគ្នា រវាងព្រឹត្តិការណ៍ពីរ ឬ ច្រើន ហើយការបញ្ចូលគ្នានេះបង្ហាញលទ្ធផលដែលអាចទៅរួចចំនួនពីរ ឬ ច្រើន។

ឧទាហរណ៍ **ព្រឹត្តិការណ៍ដែលបេក្ខជន ក ទទួលបានលទ្ធផលជាប់ ឬ ធ្លាក់** ជាព្រឹត្តិការណ៍ដែលកើតឡើងពីការបញ្ចូលគ្នារវាងព្រឹត្តិការណ៍ពីរ គឺ (១) **ព្រឹត្តិការណ៍ដែលបេក្ខជន ក ទទួលបានលទ្ធផលជាប់** និង(២) **ព្រឹត្តិការណ៍ដែលបេក្ខជន ក ទទួលបានលទ្ធផលធ្លាក់**។ ការបញ្ចូលគ្នានេះបង្ហាញលទ្ធផលដែលអាចទៅរួចបន្ទាប់ពីការប្រឡងរបស់បេក្ខជន ក ចំនួនពីរ គឺ លទ្ធផលជាប់ និង លទ្ធផលធ្លាក់។

© 2023 Udam Prang

# ព្រឹត្តិការណ៍ប្រភេទទី៤

ការបញ្ចូលគ្នា រវាងព្រឹត្តិការណ៍ពីរ ឬច្រើន តាងដោយ និម្មិតសញ្ញា “∪”។

ប្រសិនបើយើងតាង៖

- ព្រឹត្តិការណ៍ដែលបេក្ខជន ក ទទួលបានលទ្ធផលជាប់ ដោយអក្សរ P
- ព្រឹត្តិការណ៍ដែលបេក្ខជន ក ទទួលបានលទ្ធផលធ្លាក់ ដោយអក្សរ F

យើងបាន ព្រឹត្តិការណ៍ដែលបេក្ខជន ក ទទួលបានលទ្ធផលជាប់ ឬ ធ្លាក់ តាងដោយអក្សរ “P∪F”។

© 2023 Udam Prang

# ព្រឹត្តិការណ៍ប្រភេទទី៥

ព្រឹត្តិការណ៍ប្រភេទទី៥ មានលក្ខណៈស្រដៀងគ្នាទៅនឹង ព្រឹត្តិការណ៍ប្រភេទទី៤។

ព្រឹត្តិការណ៍ប្រភេទទី៥ ជា ព្រឹត្តិការណ៍ដែលកើតឡើងពីការបញ្ចូលគ្នារវាងព្រឹត្តិការណ៍ពីរ ឬ ច្រើន ហើយការបញ្ចូលគ្នានេះបង្ហាញលទ្ធផលដែលអាចទៅរួចទាំងអស់។

ឧទាហរណ៍ **ព្រឹត្តិការណ៍ដែលបេក្ខជន ក ទទួលបានលទ្ធផលជាប់ ឬ ធ្លាក់** ជាព្រឹត្តិការណ៍ដែលកើតឡើងពីការបញ្ចូលគ្នារវាងព្រឹត្តិការណ៍ពីរ គឺ (១) **ព្រឹត្តិការណ៍ដែលបេក្ខជន ក ទទួលបានលទ្ធផលជាប់** និង(២) **ព្រឹត្តិការណ៍ដែលបេក្ខជន ក ទទួលបានលទ្ធផលធ្លាក់**។ ការបញ្ចូលគ្នានេះបង្ហាញលទ្ធផលដែលអាចទៅរួចទាំងអស់ បន្ទាប់ពីការប្រឡងរបស់បេក្ខជន ក។

© 2023 Udam Prang
Not For Citation | For Educational Purposes Only

# ព្រឹត្តិការណ៍ប្រភេទទី៦

ព្រឹត្តិការណ៍ប្រភេទទី៦ ជា ព្រឹត្តិការណ៍ដែលកើតឡើងពីការប្រសព្វគ្នារវាងព្រឹត្តិការណ៍ពីរ ឬ ច្រើន។

ឧទាហរណ៍ យើងមានព្រឹត្តិការណ៍ពីរ៖

- ព្រឹត្តិការណ៍ដែលបេក្ខជន ក ទទួលបាននិទ្ទេស A ឬ និទ្ទេស B
- ព្រឹត្តិការណ៍ដែលបេក្ខជន ក ទទួលបាននិទ្ទេស A ឬ និទ្ទេស C

ការប្រសព្វគ្នារវាងព្រឹត្តិការណ៍ទាំងពីរ នឹងបណ្តាលឱ្យមានព្រឹត្តិការណ៍ថ្មីមួយទៀត គឺ

- ព្រឹត្តិការណ៍ដែលបេក្ខជន ក ទទួលបាននិទ្ទេស A

© 2023 Udam Prang

# ព្រឹត្តិការណ៍ប្រភេទទី៦

ការប្រសព្វគ្នា រវាងព្រឹត្តិការណ៍ពីរ ឬច្រើន តាងដោយ និម្មិតសញ្ញា “∩”។

ប្រសិនបើយើងតាង៖

- ព្រឹត្តិការណ៍ដែលបេក្ខជន ក ទទួលបាននិទ្ទេស A ឬ និទ្ទេស B ដោយអក្សរ X
- ព្រឹត្តិការណ៍ដែលបេក្ខជន ក ទទួលបាននិទ្ទេស A ឬ និទ្ទេស C ដោយអក្សរ Y

យើងបាន ព្រឹត្តិការណ៍ដែលកើតឡើងពីការប្រសព្វគ្នារវាង X និង Y តាងដោយអក្សរ X∩Y។

# ព្រឹត្តិការណ៍ប្រភេទទី៧

ព្រឹត្តិការណ៍ប្រភេទទី៧ ជា ព្រឹត្តិការណ៍ដែលកើតឡើងក្នុងករណីដែលព្រឹត្តិការណ៍មួយទៀតបានកើតឡើង។

ឧទាហរណ៍ យើងមានព្រឹត្តិការណ៍ពីរ៖

- ព្រឹត្តិការណ៍ដែលបេក្ខជន ក ធ្វើការស្រាវជ្រាវ
- ព្រឹត្តិការណ៍ដែលបេក្ខជន ក ទទួលបានលទ្ធផលជាប់

យើងអាចទទួលបាន ព្រឹត្តិការណ៍ពីរទៀត គឺ៖

- ព្រឹត្តិការណ៍ដែលបេក្ខជន ក ទទួលបានលទ្ធផលជាប់ ក្នុងករណីដែលគាត់បានស្រាវជ្រាវ
- ព្រឹត្តិការណ៍ដែលបេក្ខជន ក ធ្វើការស្រាវជ្រាវ ក្នុងករណីដែលគាត់ទទួលបានលទ្ធផលជាប់

© 2023 Udam Prang

# ព្រឹត្តិការណ៍ប្រភេទទី៧

ទំនាក់ទំនងរវាងព្រឹត្តិការណ៍ពីរក្នុងរូបភាពជាលក្ខខណ្ឌបែបនេះតាងដោយសញ្ញា "|"។

ប្រសិនបើយើងតាង៖

- ព្រឹត្តិការណ៍ដែលបេក្ខជន ក ធ្វើការស្រាវជ្រាវ ដោយអក្សរ R
- ព្រឹត្តិការណ៍ដែលបេក្ខជន ក ទទួលបានលទ្ធផលជាប់ ដោយអក្សរ P

យើងបាន៖

- ព្រឹត្តិការណ៍ដែលបេក្ខជន ក ទទួលបានលទ្ធផលជាប់ ក្នុងករណីដែលគាត់បានស្រាវជ្រាវ តាងដោយអក្សរ P|R
- ព្រឹត្តិការណ៍ដែលបេក្ខជន ក ធ្វើការស្រាវជ្រាវ ក្នុងករណីដែលគាត់ទទួលបានលទ្ធផលជាប់ តាងដោយអក្សរ R|P

© 2023 Udam Prang

# ២. វិធីសាស្ត្រកំណត់តម្លៃប្រូបាប៊ីលីតេ

កំណត់ដោយអត្តនោម័ត | កំណត់តាមប្រេកង់ធៀប | កំណត់តាមហេតុផលជាក់ស្តែង

© 2023 Udam Prang
Not For Citation | For Educational Purposes Only

# វិធីសាស្ត្រកំណត់តម្លៃប្រូបាប៊ីលីតេ

ប្រូបាប៊ីលីតេមានលក្ខណៈ ពីរ យ៉ាងគឺ៖

- ប្រូបាប៊ីលីតេនៃព្រឹត្តិការណ៍ណាមួយ ត្រូវតែមានតម្លៃស្ថិតនៅចន្លោះលេខសូន្យនិងលេខមួយ។
- ប្រូបាប៊ីលីតេនៃ "ព្រឹត្តិការណ៍ដែលកើតឡើងពីការបញ្ចូលគ្នារវាងព្រឹត្តិការណ៍ពីរ ឬច្រើន ហើយការបញ្ចូលគ្នានេះបង្ហាញលទ្ធផលដែលអាចទៅរួចទាំងអស់ (Exhaustive Events)" ត្រូវមានតម្លៃស្មើនឹងមួយ។

# វិធីសាស្ត្រកំណត់តម្លៃប្រូបាប៊ីលីតេ

យើងអាចកំណត់តម្លៃប្រូបាប៊ីលីតេ តាមមធ្យោបាយបីយ៉ាង៖

- កំណត់ដោយអត្តនោម័ត
- កំណត់តាមប្រេកង់ធៀប
- កំណត់តាមហេតុផលជាក់ស្តែង

© 2023 Udam Prang

# កំណត់ដោយអត្តនោម័ត

មធ្យោបាយទីមួយ គឺកំណត់ដោយអត្តនោម័ត។

ប៉ុន្តែ យើងអាចប្រើប្រាស់មធ្យោបាយនេះបាន សម្រាប់កំណត់តម្លៃប្រូបាប៊ីលីតេនៃព្រឹត្តិការណ៍ធម្មតាតែប៉ុណ្ណោះ។

# កំណត់តាមប្រេកង់ធៀប

មធ្យោបាយទីពីរ គឺកំណត់តាមប្រេកង់ធៀប។

សន្មតថា តារាងប្រេកង់ធៀបមាន ប្រាំ ថ្នាក់។

- ក្នុងភាសាប្រូបាប៊ីលីតេ ថ្នាក់នីមួយៗ គឺជា ព្រឹត្តិការណ៍។ ដូច្នេះ មាន ប្រាំ ព្រឹត្តិការណ៍ផ្សេងគ្នា។
- ប្រេកង់ធៀប សម្រាប់ថ្នាក់នីមួយៗ ឬព្រឹត្តិការណ៍នីមួយៗ គឺជា ប្រូបាប៊ីលីតេរបស់ថ្នាក់នីមួយៗ ឬព្រឹត្តិការណ៍នីមួយៗ។

© 2023 Udam Prang

# កំណត់តាមប្រេកង់ធៀប

ឧទាហរណ៍ ខាងក្រោមនេះ ទិន្នន័យស្តីពីបៀវត្សប្រចាំខែរបស់មនុស្ស ១០០ នាក់។

| ថ្នាក់បៀវត្ស (ជាដុល្លារ) | ប្រេកង់ | ប្រេកង់ធៀប |
|---|---|---|
| ក្រោម ២៥១ | ១៥ | 0,១៥ |
| ២៥១ ដល់ ៥០០ | ២៥ | 0,២៥ |
| ៥០១ ដល់ ៧៥០ | ៣៥ | 0,៣៥ |
| ៧៥១ ដល់ ១០០០ | ១៥ | 0,១៥ |
| លើស ១០០០ | ១០ | 0,១០ |
| សរុប | ១០០ | |

# កំណត់តាមប្រេកង់ធៀប

សន្មតថា យើងត្រូវការជ្រើសរើសមនុស្សម្នាក់ពីក្នុងចំណោមមនុស្សទាំង ១00 នាក់ ដើម្បីធ្វើសម្ភាស។ តាមតារាងខាងលើ យើងបាន ប្រាំ ព្រឹត្តិការណ៍ផ្សេងគ្នា៖

- ទី១៖ ព្រឹត្តិការណ៍ដែលមនុស្សម្នាក់នោះ មានបៀវត្សក្រោម ២៥១ ដុល្លារ ហើយ ប្រូបាប៊ីលីតេនៃព្រឹត្តិការណ៍នេះ គឺជា ប្រេកង់ធៀបដែលមានតម្លៃ 0,១៥។
- ទី២៖ ព្រឹត្តិការណ៍ដែលមនុស្សម្នាក់នោះ មានបៀវត្សចាប់ពី ២៥១ ដល់ ៥00 ដុល្លារ ហើយប្រូបាប៊ីលីតេនៃព្រឹត្តិការណ៍នេះ គឺជា ប្រេកង់ធៀបដែលមានតម្លៃ 0,២៥។
- ទី៣៖ ព្រឹត្តិការណ៍ដែលមនុស្សម្នាក់នោះ មានបៀវត្សចាប់ពី ៥0១ ដល់ ៧៥0 ដុល្លារ ហើយប្រូបាប៊ីលីតេនៃព្រឹត្តិការណ៍នេះ គឺជា ប្រេកង់ធៀបដែលមានតម្លៃ 0,៣៥។

# កំណត់តាមប្រេកង់ធៀប

សន្មតថា យើងត្រូវការជ្រើសរើសមនុស្សម្នាក់ពីក្នុងចំណោមមនុស្សទាំង ១00 នាក់ ដើម្បីធ្វើសម្ភាស។ តាមតារាងខាងលើ យើងបាន ប្រាំ ព្រឹត្តិការណ៍ផ្សេងគ្នា៖

- ទី៤៖ ព្រឹត្តិការណ៍ដែលមនុស្សម្នាក់នោះ មានបៀវត្សចាប់ពី ៧៥១ ដល់ ១000 ដុល្លារ ហើយប្រូបាប៊ីលីតេនៃព្រឹត្តិការណ៍នេះគឺជាប្រេកង់ធៀបដែលមានតម្លៃ 0,១៥។
- ទី៥៖ ព្រឹត្តិការណ៍ដែលមនុស្សម្នាក់នោះ មានបៀវត្សលើស ១000 ហើយ ហើយ ប្រូបាប៊ីលីតេនៃព្រឹត្តិការណ៍នេះ គឺជា ប្រេកង់ធៀបដែលមានតម្លៃ 0,១0។

© 2023 Udam Prang

# កំណត់តាមហេតុផលជាក់ស្តែង

មធ្យោបាយទីបី គឺ កំណត់តាមហេតុផលជាក់ស្តែង។

មធ្យោបាយនេះ សមស្រប នៅពេលដែលអ្នកពិសោធអាចកំណត់ចំនួនលទ្ធផលសរុប ដែលអាចកើតឡើងបន្ទាប់ពីការពិសោធបាន។

ឧទាហរណ៍ គ្រាប់ឡុកឡាក់មានមុខប្រាំមួយ។ លទ្ធផលដែលអាចកើតឡើងបន្ទាប់ពីការបោះគ្រាប់ឡុកឡាក់មានប្រាំមួយ៖ លេខ១, លេខ២, លេខ៣, លេខ៤, លេខ៥ និងលេខ៦។ តាមភាសាប្រូបាប៊ីលីតេ យើងបាន ព្រឹត្តិការណ៍សាមញ្ញចំនួនប្រាំមួយ។

- ដូច្នេះ "ប្រូបាប៊ីលីតេនៃព្រឹត្តិការណ៍សាមញ្ញ" នីមួយៗ គឺស្មើនឹង ១/៦។

# បញ្ចប់មេរៀនត្រឹមនេះ!

នៅសប្តាហ៍បន្ទាប់ យើងនឹងសិក្សាពីវិធានប្រូបាប៊ីលីតេសំខាន់ៗ។